ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

# បច្ចេកទេស
# ដាំដំណាំការ៉ុត



រៀបចំដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សហការជាមួយ

នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ នៃអគ្គនាយកដ្ឋានកសិកម្ម

ឧបត្ថម្ភការបោះពុម្ពដោយៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឆ្នាំ២០១៨

# សៀវភៅ

# ស្ដីពី

# បច្ចេកទេសដាំដំណាំការ៉ុត

## រៀបចំដោយ

**នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សហការជាមួយ**
**នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ នាយកដ្ឋានការពារដំណាំ**
**អនាម័យ និងភូតគាមអនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម**

បោះពុម្ពលើកទី១ ចំនួន ២០០០ ច្បាប់

ឧបត្ថម្ភការបោះពុម្ពដោយៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រក្សាសិទ្ធិដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# សមាសភាពចូលរួមចំណែកផលិតសៀវភៅ
# ស្តីពីបច្ចេកទេសដាំដំណាំការ៉ុត

I. ទីប្រឹក្សាផ្តល់យោបល់:

១. ឯកឧត្តមបណ្ឌិត **ងិន ឆាយ** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកសិកម្ម

២. បណ្ឌិត **ម៉ៅ មិនា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. បណ្ឌិត **គៀន សុភា** នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ

៤. លោក **គឹម ដារ៉ា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

II. អ្នករៀបរៀង:

១. លោក **ផាន ទូច** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

III. អ្នកស្រាវជ្រាវ:

១. លោក **ផន ប្រុស** នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ

២. លោក **អន វណ្ណៈ** នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ។

IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

១. លោក **ជីម ចាន់ណា** នាយកដ្ឋានការពារដំណាំ អនាម័យនិងភូតគាមអនាម័យ

២. លោក **ហុខ ទ្រី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. លោក **ស្រេខ ឫទ្ធី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។





# មាតិកា

ទំព័រ


I. សេចក្ដីផ្ដើម..........................................................................................................១
II. លក្ខខណ្ឌបរិស្ថាន................................................................................................៣
១. លក្ខខណ្ឌដីដាំដុះ..................................................................................................៣
២. លក្ខខណ្ឌអាកាសធាតុ..........................................................................................៤
III. លក្ខណៈរូបសាស្ត្រ................................................................................................៤
១. ផ្កា ....................................................................................................................៤
២. គ្រាប់..................................................................................................................៥
៣. ស្លឹក..................................................................................................................៥
៤. មើម...................................................................................................................៦
IV. ការជ្រើសរើសពូជការ៉ុត.......................................................................................៧
V. បច្ចេកទេសដាំដុះ.................................................................................................៧
១. ការរៀបចំដី.........................................................................................................៧
២. ការដាំដុះ............................................................................................................៨
VI. ការប្រើប្រាស់ជី...................................................................................................១០
១. ពេលវេលា និងកម្រិតនៃការប្រើប្រាស់ជី.................................................................១០
VII. ការថែទាំ...........................................................................................................១១
១. ការស្រោចស្រពលើដំណាំការ៉ុត...............................................................................១១
២. ការសំអាតស្មៅចង្រៃ...........................................................................................១២
VIII. អំពីជំងឺ និងសត្វល្អិតចង្រៃលើដំណាំការ៉ុត..........................................................១៣
១. ជំងឺលើដំណាំការ៉ុត...............................................................................................១៣
២. សត្វល្អិតលើដំណាំការ៉ុត.......................................................................................១៨
IX. ការប្រមូលផល.....................................................................................................២០
១. បច្ចេកទេសក្រោយពេលប្រមូលផល.......................................................................២១
២. ការជ្រើសរើស ឬបែងចែកចំណាត់ថ្នាក់..................................................................២២
៣. ការវេចខ្ចប់...........................................................................................................២២
៤. ការស្ដុកទុក...........................................................................................................២៣
៥. ការដឹកជញ្ជូន........................................................................................................២៣

# ដំណាំការ៉ុត (Daucus Carota Sutsp.Satnus)

## I.សេចក្តីផ្តើម

កា៉រុត គឺជាដំណាំមួយប្រភេទ ដែលត្រូវបានគេដាំដុះនៅពាសពេញពិភពលោក។ ចំនួនផលិតផលដំណាំការ៉ុតនៅលើពិភពលោកសរុបស្មើនឹង ៦០% បើប្រៀបធៀបទៅនឹងដំណាំផ្សេងៗទៀត ដំណាំការ៉ុតនៅតំបន់អាស៊ីភាគច្រើន មានការនិយមដាំដុះតែចំពោះប្រភេទការ៉ុតដែលមានសំបកពណ៌ស្វាយ ក្រហម រាងលឿង និងពណ៌ទឹកក្រូចជាដើម។ ជាទូទៅដំណាំការ៉ុតជាដំណាំមានអាយុកាលពី ១ឆ្នាំឬអាចដល់ពីរឆ្នាំ អាស្រ័យទៅលើប្រភេទពូជរបស់វា ហើយវាអាចដាំដុះបានទាំងនៅតំបន់ត្រូពិច និងស៊ុបត្រូពិច។ ដំណាំការ៉ុតស្ថិតនៅក្នុងគ្រួសារ Apiaceae និងមានអំបូរឈ្មោះ Daucus វាមានប្រភពកំណើតមកពីទ្វីបអឺរ៉ុប និងតំបន់អាស៊ីបូពាណ៌ ហើយដំណាំនេះ



គេអាចធ្វើការប្រើប្រាស់ និងហូបចុកនៅផ្នែកមើមដោយវាបានផ្តល់នូវអត្ថប្រយោជន៍ ច្រើនដល់សុខភាពនេះ បើយោងតាមការសិក្សាស្រាវជ្រាវតាមលក្ខណៈវិទ្យាសាស្ត្រ និងកត្តារួមផ្សំផ្សេងៗទៀត។ បានបង្ហាញឱ្យឃើញថា ដំណាំនេះគេអាចយកវាទៅធ្វើការដាំដុះនៅក្នុងផើង និងក្នុងឧបករណ៍ផ្សេងៗទៀតជាពិសេសត្រូវបានគេយកទៅដាំដុះក្នុងលក្ខខណ្ឌជាផ្ទះកញ្ចក់ និងប្លាស្ទីកជាដើម។

ជាងនេះទៀត ដំណាំការ៉ុត អាចជួយបង្កើនសុខភាពភ្នែក ស្បែក ប្រព័ន្ធប្រសាទ រាងកាយ បេះដូង និងប្រព័ន្ធការពារជំងឺផ្សេងៗទៀតផង ដែរ។ មើមការ៉ុតងាយស្រួលដាំដុះ និងប្រមូលផល។ ការ៉ុតមានរសជាតិ ឆ្ងាញ់ ដោយសារមើមមានរស់ជាតិ Carotene ច្រើន ដែលរាងកាយមនុស្ស អាចចម្រាញ់ទៅជា Vitamine A ។ Carotene គឺជាសារជាតិមានពណ៌លឿង ទុំ មាននៅក្នុងមើមការ៉ុត ផ្លែល្ពៅមើមដំឡូងពណ៌លឿង ផ្លែម្ទេសក្រហម ជាដើម ផលប្រយោជន៍មើមការ៉ុតក្រោយការបរិភោគរួច ជួយឱ្យភ្លឺភ្នែក និងកាត់បន្ថយគ្រោះថ្នាក់មហារីកសួត។

ការ៉ុតគឺជាប្រភពដ៏សំខាន់ ក្នុងការផ្តល់ជីវជាតិ មានដូចជាវីតាមីន អា(A) ជំនួយសុខភាពភ្នែក។ នៅប្រទេសកម្ពុជា មានស្ត្រី និងកុមារភាគ ច្រើនមានជំងឺខ្វាក់មាន់ បណ្តាលមកពីកង្វះរបបអាហាមិនមានជីវជាតិ គ្រប់គ្រាន់ ។ ការ៉ុតតូច ទម្ងន់ ៥០ក្រាម អាចផ្តល់ វីតាមីន អា ច្រើនជាង ១៥០% នៃបរិមាណវីតាមីន អា ដែលបានទទួលទានប្រចាំថ្ងៃ។ ការ៉ុត ជាប្រភពអាហារដែលមានជាតិសសៃ ជាតិខ្លាញ់ និងកាឡូរីទាប។ ការ៉ុត ឆៅដែលសកសំបកចេញ អាចបរិភោគលេងបានសម្រាប់កុមារ និងយុវ វ័យ។ មិនតែប៉ុណ្ណោះការ៉ុត គេអាចយកទៅស្ងោរហើយកិនឱ្យម៉ត់ដាក់ ក្នុងរបបអាហារ ប្រចាំថ្ងៃរបស់ទារកក៏បាន ។





| សារធាតុចិញ្ចឹម | ភាគរយនៃសារធាតុចិញ្ចឹម ក្នុងផ្លែការ៉ុត ស្រស់ | ភាគរយនៃសារធាតុចិញ្ចឹមក្នុង ផ្លែការ៉ុត ក្រោយចំអិនរួច |
|---|---|---|
| កាល់ស្យូម | ៤% | ៤% |
| សារធាតុសសៃរ | ១៤% | ១៨% |
| ជាតិដែក | ២% | ២% |
| ជាតិម៉ង់កាណែស | ៩% | ១២% |
| ប៉ូតាស្យូម | ១២% | ១០% |
| វិតាមីនA | ៤២៨% | ៥៣២% |
| វិតាមីនB6 | ៩% | ១២% |
| វិតាមីនC | ១៣% | ១៨% |
| វិតាមីនE | ៤% | ៨% |
| វិតាមីនK | ២១% | ២៦% |

## II. លក្ខខណ្ឌបរិស្ថាន

### ១. លក្ខខណ្ឌដីដាំដុះ



ជាទូទៅដំណាំការ៉ុត គឺជាដំណាំដែលអាច ធ្វើការដាំដុះនៅក្នុងតំបន់ត្រជាក់ មានសីតុណ្ហភាពចន្លោះពី ១៥ ទៅ ២១ °C ព្រោះសីតុណ្ហភាព កម្រិតនេះ អាចធ្វើឱ្យពណ៌របស់មើមល្អ។ ដំណាំ

ការ៉ុត អាចដុះលូតលាស់បានល្អ លុះត្រាដីមានជីជាតិគ្រប់គ្រាន់(មានសារធាតុសរីរាង្គច្រើន និងមាន pH ចាប់ពី ៥.៥ ទៅ ៦ ទើបអាចទទួលបានទិន្នផលខ្ពស់)។

២. លក្ខខណ្ឌអាកាសធាតុ

ដំណាំការ៉ុតអាចដុះលូតលាស់បានល្អ នៅតំបន់ដែលមានអាកាសធាតុត្រជាក់ក្នុងកម្រិតសីតុណ្ហភាពចន្លោះពី១៥-២១ អង្សាសេ និងកម្រិតសីតុណ្ហភាពចន្លោះពី ១៧ ទៅ ២៤អង្សាសេ ជាលក្ខខណ្ឌល្អបំផុតសម្រាប់ការដុះលូតលាស់របស់ដំណាំការ៉ុត។ វាជាប្រភេទដំណាំមានការដាំដុះប្រចាំឆ្នាំ និងអាចដុះលូតលាស់បានល្អក្នុងតំបន់ដែលមានរបបទឹកភ្លៀងប្រចាំឆ្នាំសមស្រប ប៉ុន្តែក៏ត្រូវការដីដែលមានប្រព័ន្ធបញ្ចេញបញ្ចូលទឹកបានល្អ និងមានជីកំប៉ុស្តច្រើន។

ត្រូវជ្រើសរើសទីតាំងដែលមានពន្លឺព្រះអាទិត្យគ្រប់គ្រាន់ ព្រោះដំណាំប្រភេទនេះ មិនអាចដុះលូតលាស់បានល្អនៅតំបន់ដែលមានសីតុណ្ហភាពឡើងខ្ពស់ ឬមានភ្លៀងធ្លាក់ច្រើន និងពេញមួយឆ្នាំនោះទេព្រោះអាចធ្វើឱ្យទិន្នផលដំណាំការ៉ុតធ្លាក់ចុះ។

## III. លក្ខណៈរូបសាស្ត្រ

១. ផ្កា:

ដំណាំការ៉ុតមានផ្កា អាចរហូតដល់១០០០ផ្កា ។ ផ្ទៃខាងក្រៅរបស់ផ្កាមានភាពចាស់ ឬរីកមុន រហូតល់ដល់ផ្ទៃកណ្តាលរបស់ផ្កា និងចង់លម្អង។ ផ្កានីមួយៗមាន៥ត្របក បំពង់កេសរឈ្មោលមាន៥ និង បំពង់កេសញីមាន២ ហើយវាមានអូវុល២ដែរ។ ដំណាំការ៉ុតវាមានស្វ័យដំណើរលម្អងដោយផ្ការបស់វា មានគ្រប់លក្ខណៈ (perfect flowers) និងមានរាងជាកញ្ចុំៗ ហើយគេអាចធ្វើការបង្កាត់បានដែរ ដោយក្នុងបំណងចង់បានពូជសុទ្ធជាដើម។





## ២. គ្រាប់

គ្រាប់របស់ដំណាំការ៉ុត ផលិតឡើងតាមរយៈដំណើរបង្កាត់លម្អង ដើម្បីបង្កើនភាពសុទ្ធ មានលក្ខណៈឯកសណ្ឋាន និងមានដំណុះគ្រាប់ល្អជាដើម។

គ្រាប់ដំណាំការ៉ុតមានទំហំតូច ជាមធ្យមទំហំរបស់វាគឺ១ម.ម និងមានពណ៌ត្នោត និងមានចំនួន២៣,០០០ គ្រាប់ក្នុង១ កញ្ចុំផ្កា គ្រាប់របស់វាមានអំប្រិយ៉ុង មានអត្រាដំណុះខ្ពស់ ហើយកូនរបស់វានេះមានភាពរឹងមាំល្អ។





## ៣. ស្លឹក

ស្លឹករបស់ដំណាំការ៉ុត គេអាចបរិភោគបាន ដូចមើមរបស់វាដែរ ក្នុង១ដើមវាមានស្លឹកចំនួនពី៨ទៅ១២ទងស្លឹក នៅផ្នែកខាងលើដី និងផ្នែកគល់នៅក្រោមដី ហើយស្លឹករបស់វាមានពណ៌បៃតងខ្ចី ដោយផ្ទៃស្លឹក

របស់ វាមានលក្ខណៈឆែកៗ។




## ៤. មើម

ដំណាំការ៉ុត គេតែងបរិភោគមើមភាគច្រើន ហើយមើមរបស់វាមានពណ៌ស៊ីជំពូ ក្រមៅ ក្រហម ស និងលឿងជាដើម។ វាមានភាពលូតលាស់ផ្នែកខាងស្លឹក នៅដំណាក់កាលដំបូង កាលណាស្លឹកវាលូតលាស់ខ្លាំង មើមឫសកែវរបស់វាក៏លូតលាស់ខ្លាំងដែរ។ ឫសកែវរបស់ដំណាំការ៉ុត វាមានការកកើតឡើងដោយសារ hypocotyl ជាមួយនឹងឫសរយាង ដែលតភ្ជាប់មកពីបំពង់ xylem។ ជាមួយគ្នានេះដែរ ឫសកែវ និង hypocotyl ផ្សំគ្នាបង្កើតបានទៅជាមើមការ៉ុត។ មើមដំណាំការ៉ុត វាមានទំហំ និងទ្រង់ទ្រាយប្រែប្រួលអាស្រ័យទៅតាមប្រភេទដី និងលក្ខខណ្ឌអាកាសធាតុ ហើយមើមរបស់វាមិនមានថ្នាំងទេ។




## IV. ការជ្រើសរើសពូជការ៉ុត

ដំណាំការ៉ុតមានពូជច្រើនប្រភេទនៅទ្វីបអាស៊ីយើងនេះ ដោយមានពូជខ្លះកំពុងធ្វើការដាំដុះ និងទទួលបាននូវការពេញនិយមនៅតំបន់នេះផងដែរ ដែលពូជទាំងនោះមានដូចជា Mini sweet, Hybreed sun Rise red និងពូជផ្សេងទៀត។ គ្រាប់ពូជត្រូវមានអត្រាដំណុះខ្ពស់ និងមានភាពធន់ទៅនឹងកត្តាចង្រៃផ្សេងៗ ព្រមទាំងមានទិន្នផលខ្ពស់។ ជាពិសេសត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- ពូជត្រូវមានប្រភពច្បាស់លាស់ (ពូជក្នុងស្រុកឬពូជបង្កាត់)
- ពូជមានអាយុកាលកំណត់ត្រឹមត្រូវ
- ពូជមានអត្រាដំណុះចាប់ពី ៨៥-៩០ %
- ពូជធន់ទៅនឹងការប្រែប្រួលអាកាសធាតុ សត្វល្អិត និងជំងឺ។





## V. បច្ចេកទេសដាំដុះ

### ១. ការរៀបចំដី:

ទីតាំងចម្ការ ត្រូវបានជ្រើសរើស និងរៀបចំឱ្យបានល្អ និងត្រូវធ្វើការភ្ជួររាស់ដីឱ្យបានចាប់ពី៣ ទៅ ៤ដង ដោយត្រូវធ្វើការសំអាតដី និងរាស់ដីឱ្យបានរាបស្មើល្អ ត្រូវហាលដីឱ្យបានពី៧-១០ថ្ងៃ ។

ត្រូវធ្វើការដាក់ជីកំប៉ុស្តចំនួន២៥តោន/ហ.ត ទ្រាប់បាត ក្នុងពេលភ្ជួររាស់ឱ្យបានត្រឹមត្រូវ និងធ្វើការសំអាតស្មៅមុនពេលដាក់ជី រីឯទំហំរងត្រូវលើកទទឹង១ម៉ែត្រ និងបណ្ដោយអាស្រ័យទៅតាមលទ្ធភាពដី ឬសារធាតុសរីរាង្គផ្សេងៗចំនួន១.៥-២គ.ក្រក្នុងផ្ទៃដី១ម៉ែត្រការ៉េ និងត្រូវកប់ក្នុងជម្រៅពី២៥-៣០ ស.ម។





### ២. ការដាំដុះ

### ២.១. ការជ្រើសរើសទីតាំង

មុនដាំត្រូវធ្វើការជ្រើសរើសទីតាំងដូចជា ដីមិនលិចទឹក អាចធ្វើការដាំដុះបានពេញមួយឆ្នាំ( ទាំងរដូវប្រាំង និងរដូវវស្សា ) នៅជិតប្រភពទឹក មានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ មិនស្ថិតនៅក្រោមម្លប់ឈើ ជាទីតាំងដែលមានពន្លឺព្រះអាទិត្យគ្រប់គ្រាន់។

### ២.២. ការដាំ

- ដំណាំការ៉ុតជាទូទៅគេតែងដាំដោយគ្រាប់ផ្ទាល់ ព្រោះវាបានផ្ដល់មើមវែងល្អ ចំពោះការដាំត្រូវប្រើប្រាស់គ្រាប់ពូជចន្លោះពី៥-៦គ.ក្រក្នុង១ហិកតា

- ឫសកែវដំណាំការ៉ុតមានការរីកលូតលាស់លឿន ហើយឫសកែវនេះហើយ ដែលបានវិវត្តន៍ទៅជាមើមការ៉ុត

- ត្រូវលើករង ទំហំ ៨០-១០០ ស.ម កម្ពស់ ១៥-២០ ស.ម នៅ

រដូវប្រាំង និង២០-២៥ ស.ម នៅរដូវស្សា

- ត្រូវយកគ្រាប់ពូជទៅដាក់ហាលឱ្យត្រូវកម្ដៅថ្ងៃរយៈពេលពី២-៣ ម៉ោង បន្ទាប់មកត្រូវយកគ្រាប់ទៅត្រាំទឹកក្ដៅអ៊ុនៗចំនួនពី២៥ទៅ៣០ នាទី មុនពេលយកទៅដាំដើម្បីសម្លាប់មេរោគ ដែលបានជាប់មកជាមួយគ្រាប់ដំណាំ។



គ្រាប់ពូជដំណាំការ៉ុត



ការដាំគ្រាប់ពូជការ៉ុត

- ចន្លោះគុម្ពប្រវែង ៣០ ស.ម ចន្លោះជួរ ឬដើមប្រវែង៨០ស.ម

- ត្រូវសាបគ្រាប់នៅជម្រៅ១,៥ ស.ម នៅពេលដំណាំដុះញឹកពេកត្រូវដក ឬកាត់ចោលខ្លះ ដោយរក្សាចន្លោះពីដើមមួយទៅដើមមួយទៀតចម្ងាយ១០ ស.ម និងត្រូវបន្ថែមកាកសំណល់ជាគម្របដី ដើម្បីរក្សាសំណើម និងការពារស្មៅចង្រៃ។

- ត្រូវធ្វើការសំអាតគ្រាប់ពូជឱ្យបានល្អ ត្រូវយកផ្សិត Tricoderma ចំនួន៥% លាយជាមួយគ្រាប់ពូជមុនធ្វើការដាំដុះ។

ការដាំដុះជាទូទៅដំណាំការ៉ុតគេតែងដាំដោយគ្រាប់ផ្ទាល់ក៏ប៉ុន្តែមុនដាំ ត្រូវយកគ្រាប់ពូជទៅលាយជាមួយដីខ្សាច់ ដោយគ្រាប់ពូជចំនួន១ភាគ និងដីខ្សាច់ចំនួន៤ភាគ ដើម្បីឱ្យគ្រាប់ពូជមិនស្អិតជាប់គ្នា និងដុះលូតលាស់បានឆាប់រហ័ស។

## VI. ការប្រើប្រាស់ជី

មុនធ្វើការប្រើប្រាស់ជី ចាំបាច់ត្រូវធ្វើការវិភាគរកកម្រិតសារធាតុចិញ្ចឹមដែលមាននៅក្នុងដីជាមុនសិន។ ត្រូវធ្វើឱ្យដីមានសំណើមដើម្បីឱ្យជីងាយរលាយ នៅពេលដំណាំការ៉ុតមានកម្ពស់ ៥ ស.ម ត្រូវធ្វើការដាក់ជីកែង(១៥.១៥.១៥) ចំនួន១០ក្រាម ក្នុង១ម៉ែត្រការ៉េ និងដាក់ជីកំប៉ុស្តចំនួន១.៥ គ.ក្រ - ២ គ.ក្រ លើផ្ទៃដី១ម៉ែត្រការ៉េ ឬអាចប្រើជី NPK (១៦.១៦.0) ចំនួន២ kg និងជីកំប៉ុស្តចំនួន១៥0kgលើផ្ទៃដី១០០ម$^{២}$ សម្រាប់ទ្រាប់បាត



គំនរជីកំប៉ុស្ត



សកម្មភាពដាក់ជីទ្រាប់បាត

### ១. ពេលវេលា និងកម្រិតនៃការប្រើប្រាស់ជី

- ការដាក់ជីលើកទី១ ត្រូវដាក់បន្ទាប់ពីដាំបាន៥-៧ថ្ងៃ ត្រូវដាក់ជីអ៊ុយរ៉េក្នុងកម្រិត១០ក្រាមលើផ្ទៃដី១ម៉ែត្រការ៉េ និងដាក់ជី ១៥.១៥.១៥ ចំនួន១០ ក្រាមលើផ្ទៃដី១ម៉ែត្រការ៉េ
- ការដាក់ជីលើកទី២ ត្រូវដាក់ជី ១៥.១៥.១៥ ក្នុងកម្រិត១០ក្រាមលើផ្ទៃដី១ម៉ែត្រការ៉េ បន្ទាប់ពីដាំបានចំនួន១៤ថ្ងៃ
- ការដាក់ជីលើកទី៣ ត្រូវដាក់ជី១៥.១៥.១៥ ក្នុងកម្រិត១៥-២០ក្រាមលើផ្ទៃដី១ម៉ែត្រការ៉េ។



ប្រភេទជី កំប៉ុស្ដ



ប្រភេទជី ១៥.១៥.១៥

អាចប្រើប្រាស់ជីលាមកសត្វ និងកំប៉ុស្ដ ចំនួន ១០ទៅ១៥តោន លើផ្ទៃដី១ហិកតា។ ត្រូវដាក់មុនពេលរៀបចំដី ឬមុនពេលភ្ជួរលុប ត្រូវលាយឱ្យបានស្មើសាច់ល្អ អាចបង្កើនរហូតដល់២០តោន បើមានលទ្ធភាពរកបាន នឹងអាចប្រើប្រាស់សារធាតុ Znso4 ចំនួន២៥kg/ha បន្ថែមដើម្បីលាយជាមួយជីទ្រាប់បាត។



លាមកសត្វ



ប្រភេទជី កំប៉ុស្ដ

## VII. **ការថែទាំ**

### ១. ការស្រោចស្រពលើដំណាំការ៉ុត:

- ត្រូវផ្ដល់ទឹកឱ្យបានគ្រប់គ្រាន់ដល់ស្រទាប់ដីខាងលើ នៅពេលដាំគ្រាប់ពូជ ត្រូវធ្វើការស្រោចស្រពឱ្យបាន២-៣ ដងក្នុង១ថ្ងៃ ដើម្បីឱ្យ

កូនការ៉ុតដុះលូតលាស់បានល្អ

- បន្ទាប់ពីការដុះពន្លកត្រូវធ្វើការស្រោចស្រពឱ្យបាន២ដងក្នុងមួយថ្ងៃ គឺពេលព្រឹក និងពេលល្ងាច

- ចំពោះការស្រោចស្រពនៅរដូវវស្សា ត្រូវធ្វើនៅចន្លោះពេលដីស្ងួតបានហើយ

- ត្រូវមានប្រព័ន្ធសម្រាប់បង្ហូរទឹកចេញ-ចូលនៅតាមចន្លោះរងនីមួយៗ

បន្ទាប់ពីបានធ្វើការស្រោច នៅពេលរសៀល ហើយត្រូវធ្វើការគ្របរងឱ្យបានល្អ ដើម្បីការពារការបាត់បង់ទឹក ដោយរំហួត នៅក្នុងអំឡុងពេលអាកាសធាតុ ឡើងកម្ដៅខ្លាំង និងថែមទាំងធ្វើឱ្យដំណាំការ៉ុតលូតលាស់បានឆាប់រហ័ស។



ការស្រោចស្រព



ចន្លោះរងមានចង្អូរបង្ហូរទឹក

## ២. ការសំអាតស្មៅចង្រៃ:

ការកម្ចាត់ស្មៅចង្រៃ ត្រូវធ្វើឡើងឱ្យបានទៀងទាត់ ជៀសវាងការបាត់បង់សារធាតុចិញ្ចឹម ធ្វើឱ្យដំណាំលូតលាស់មិនល្អ អាចបំបាត់ជម្រកសត្វចង្រៃផ្សេងៗ អាចប្រើប្រាស់ថ្នាំពុលកំចាត់ស្មៅចំនួន១លីត្រនៃធាតុ

សកម្មថ្នាំ(a.i) សម្រាប់ផ្ទៃដី/ហាត។ ចំពោះការធ្វើស្មៅជាលើកដំបូង គឺនៅពេលដែលកូនដំណាំមានអាយុចាប់ពី១៥ថ្ងៃឡើងទៅ ។




*សកម្មភាពនៃការកម្ចាត់ស្មៅក្នុងចម្ការដំណាំការ៉ុត*

## VIII. អំពីជំងឺ និងសត្វល្អិតចង្រៃលើដំណាំការ៉ុត

### ១. ជំងឺលើដំណាំការ៉ុត

### ១.១. ជំងឺអុចស្លឹកការ៉ុត:

Carrot leaf spot បង្កដោយផ្សិតឈ្មោះ Alternaria dauci

**រោគសញ្ញា:**

ស្លឹកដែលចាស់គឺទទួលរងការបំផ្លាញដំបូងគេ។ ស្នាមពណ៌ប្រផេះចាស់ ប្រែទៅជាចំណុចអុចៗពណ៌ត្នោត រាងជាជ្រុងជាមួយនឹងស្នាមពណ៌លឿងនៅជុំវិញកើតឡើងនៅលើស្លឹក និងទងស្លឹក។ នៅក្នុងលក្ខខណ្ឌ អំណោយផលចំណុចអុចៗទាំងនោះបានរាលដាលចូលគ្នា ហើយធ្វើឱ្យស្លឹកទាំងនោះប្រែទៅជាខ្មៅ ក្រៀម និងងាប់។ ស្ព័ររបស់ផ្សិតក៏បានរាលដាលបន្តពីស្លឹកចាស់ទៅដល់ត្រួយរបស់ដំណាំផងដែរ។ ផ្សិតប្រភេទនេះអាចកើតមានពេលដំណាំនៅដំណាក់កាលកូនតូចៗទាំងមុន និងក្រោយដំណុះគ្រាប់ធ្វើឱ្យកូនការ៉ុតងាប់(damping off)។ ផ្សិតប្រភេទនេះ (Alternaria) អាចរស់បន្តទៅរដូវក្រោយទៀត ដោយស្នាក់អាស្រ័យនៅ

ក្នុងដី និងនៅក្នុងគ្រាប់ពូជផងដែរ។




ជំងឺអុចស្លឹកការ៉ុត ( Carrot leaf spot )

**ចំណាំ:**

ជំងឺប្រភេទនេះស្រដៀងគ្នាជាមួយជំងឺមួយទៀតដែលបង្កឡើងដោយពពួកផ្សិតមួយប្រភេទផ្សេងទៀតគឺ Cercospora carotae មានស្នាមជារង្វង់ ឬអុចៗពណ៌ប្រផេះកើតមាននៅលើស្លឹក និងទងស្លឹក ហើយបើនៅក្នុងលក្ខខណ្ឌអាកាសធាតុមានសំណើមខ្លាំង អាចបណ្តាលឱ្យកើតជាស្នាមរលាកនៅលើស្លឹក។

**វិធានការការពារ:**

~ ប្រើប្រាស់ពូជដែលធន់ទ្រាំបើសិនអាចរកបាន ពិសេសគ្រាប់ពូជដែលមិនមានជាប់មកជាមួយនូវ ពពួកផ្សិត Alternaria និង Cercospora.

~ ប្រើប្រាស់គ្រាប់ពូជដែលបានទទួលស្គាល់ និងសម្អាតស្អាតល្អ ឬគ្រាប់ពូជដែលបានយកទៅធ្វើប្រព្រឹត្តកម្មនឹងទឹកក្តៅ ៥០អង្សាសេ ក្នុងរយៈពេល២០នាទី។

~ បណ្តុះកូនការ៉ុតជាមួយដីដែលបានសំលាប់មេរោគ និងនៅក្នុងថាសបណ្តុះដែលស្អាតល្អ។ ធ្វើការ ត្រួតពិនិត្យតាមដានជាប្រចាំកូនដែលមានរោគសញ្ញាត្រូវដក់ចោល។

~ កាត់ប្រមូលដើមការ៉ុតដែលដុះមូរចេញពីចម្ការ ព្រោះវាជាប្រភពនៃការចម្លងរោគ

~ ជៀសវាងការដាំដំណាំនៅផ្នែកខាងក្រោមខ្យល់ ឬផ្នែកបន្ទាប់ចម្ការធ្លាប់មានជំងឺព្រោះអាចឆ្លងរាលដាលតាមខ្យល់ និងទឹកទៅចម្ការផ្សេងទៀត

~ ត្រូវបន្ថែមជីធម្មជាតិ នៅស្រទាប់ដីខាងលើ។ ការបាត់បង់សារធាតុចិញ្ចឹម ពិសេសការខ្វះសារធាតុ ប៉ូតាស្យូម អាចបង្កើនភាពងាយរងគ្រោះដោយជំងឺដល់ដំណាំការ៉ុត

~ ប្រសិនបើអាច ប្រើប្រាស់ប្រព័ន្ធស្រោចស្រពជាចង្អូរៗ នោះនឹងអាចគ្រប់គ្រងការងារស្រោចស្រពបានល្អបំផុត។ ជៀសវាងការប្រើប្រាស់ប្រព័ន្ធស្រោចស្រពក្រៅពីនេះដែលអាចនាំឱ្យស្លឹកការ៉ុតសើម និងជំរុញ ដល់ការរីករាលដាលនៃជំងឺ

~ ស្រោចស្រពនៅពេលថ្ងៃដើម្បីទុករយៈពេលឱ្យដំណាំស្ងួត ការស្រោចស្រពនៅពេលយប់នឹងធ្វើឱ្យដំណាំសើម និងជំរុញដល់ការវិវឌ្ឍន៍របស់ជំងឺ

~ ត្រូវដាំដំណាំនៅលើថ្នាលដែលខ្ពស់ និងចន្លោះរងធំទូលាយដើម្បីឱ្យទឹកហូរធ្វើឱ្យដីឆាប់ស្រស់ទឹក

~ ត្រូវរក្សាទុកការ៉ុតដែលគ្មានស្នាមរបួស ព្រោះការ៉ុតដែលរងរបួសស្នាមងាយនឹងឆ្លងជំងឺ

~ សម្អាតសម្ភារម៉ាស៊ីនផ្សេងៗបន្ទាប់ពីប្រើប្រាស់ដំបូងព្រោះវាអាចចម្លងជំងឺបាន

~ ប្រមូលយកកម្ទេចកម្ទីកាកសំណល់ដំណាំចេញពីចម្ការបន្ទាប់ពីប្រមូលផលរួច ដើម្បីការពារវត្តមានស្ព័រផ្សិតបន្តចម្លងនៅពេលដាំដុះនៅរដូវបន្ទាប់

~ ត្រូវដាំដំណាំបង្វិល យ៉ាងហោចណាស់ពនឆ្នាំម្តង ជាមួយនឹង

ដំណាំដែលមិនងាយទទួលរងការឆ្លងជំងឺ។ ហាមដាំដំណាំបង្វិលជាមួយនឹងដំណាំផ្សេងៗដូចជា ខ្ទឹម ស្ពៃក្តោប ត្រសក់ សាលាដ ប៉េងប៉ោះ...។

**វិធានការកម្ចាត់:**

~ ការធ្វើប្រព្រឹត្តកម្មគ្រាប់ពូជ ធ្វើការសំអាត ឬត្រាំគ្រាប់ពូជជាមួយថ្នាំដែលមានសារធាតុសកម្មដូច ជា Thiram ឬ Captan ដើម្បីការពារកូនដំណាំពីការរលួយ។

~ ដើម្បីការពារ និងកម្ចាត់ផ្សិតប្រភេទនេះកសិករ ឬអ្នកដាំដុះ អាចប្រើប្រាស់ថ្នាំគីមីកសិកម្មដែលមាន ធាតុសកម្មដូចជា ៖ Iprodione, Copper formulations, Mancozeb និង Chlorothalonil។

### ១.២. ជំងឺរលាកបង្កដោយបាក់តេរី (bacterial blight of carrot):

ជំងឺប្រភេទនេះបង្ករឡើងដោយបាក់តេរីឈ្មោះ Xanthomonas hortorum pv. carotae

**រោគសញ្ញា:**

រោគសញ្ញានៃការរលាកដោយបាក់តេរីនេះគឺ ដំបូងលេចចេញជាស្នាមពណ៌លឿងតូចៗដែលមានសណ្ឋាន ជាជ្រុងៗនៅលើកោសិកានៃស្លឹក។ ចំណុចកណ្តាលនៃកន្លែងដែលកើតនោះក៏ចាប់ផ្តើមប្រែទៅជាស្ងួត និងមានចំណុចអុចៗពណ៌ត្នោតជាមួយនឹងនឹងស្នាមពណ៌លឿងព័ទ្ធជុំវិញ។



*ជំងឺរលាកបង្កដោយបាក់តេរី (bacterial blight of carrot)*

**វិធានការការពារ និងកម្ចាត់:**

វិធានការចម្បងៗនៃការគ្រប់គ្រង ជំងឺរលាកបង្កដោយបាក់តេរី រួមមាន ៖

~ ធ្វើការដាំដុះតែកូនដំណាំដែលមិនមានជំងឺ ឬកូនដំណាំដែលមានសុខភាពល្អ

~ ធ្វើការប្រឡាក់គ្រាប់ពូជជាមួយថ្នាំគីមីកសិកម្មដូចជាពពួក Copper ជាដើម

~ អនុវត្តវិធីសាស្ត្រដាំដំណាំបង្វិលរៀងរាល់២ទៅ៣ឆ្នាំម្តង ឬភ្ជួរលប់កាកសំណល់កម្ទេចកម្ទីឱ្យបានស្អាតល្អ

~ ការប្រើប្រាស់ថ្នាំបាក់តេរីដែលមានធាតុសកម្ម Copper គឺអាចពន្យាពេលនៃការវិវឌ្ឍន៍របស់ជំងឺ ពិសេសការបាញ់ថ្នាំនៅដំណាក់កាលដំបូង (ដំណាក់កាលការ៉ុតនៅតូច)។

**១.៣.ជំងឺរលួយទន់បង្ករដោយបាក់តេរី (Bacterial Soft Rot on Carrots):**

បង្ករដោយបាក់តេរីឈ្មោះ Pectobacterium carotovorum ដែលពីមុនគេហៅឈ្មោះថា Erwinia carotovora.



*ជំងឺបាក់តេរីរលួយទន់បង្ករដោយបាក់តេរី (Bacterial Soft Rot on Carrots )*

**វិធានការការពារ:**

~ ការ៉ុតជាដំណាំដែលត្រូវការស្រស់ទឹកឱ្យបានល្អ ដូចនេះការ

ស្រោចទឹកត្រូវមានការយកចិត្តទុកដាក់អាចស្រោច២ដងក្នុងមួយសប្តាហ៍ទៅតាមរដូវកាលដាំដុះ។

~ អាចដាំបង្វិលជាមួយនឹងដំណាំផ្សេងៗទៀតដូចជា សណ្តែកបារាំង សណ្តែងសៀង និងពពួកស្មៅចំណីសត្វជាដើម។

~ជៀសវាងធ្វើឱ្យមានរបួសស្នាមទៅលើការ៉ុតទាំងនៅដំណាក់កាលតូចៗ ឬនៅដំណាក់កាលប្រមូលផលគឺដើម្បីការពារពីការជ្រាតចូលនៃភ្នាក់ងារបង្ករោគផ្សេងៗ។

~ ត្រូវចាប់ផ្តើមធ្វើការថែទាំនៅតំបន់ដែលគ្មានជំងឺឬកន្លែងរុក្ខជាតិមានសុខភាពល្អបន្ទាប់មកទើបធ្វើការថែទាំនៅតំបន់ដែលមានការរាតត្បាតពីជំងឺ ធ្វើបែបនេះគឺដើម្បីការពារពីការចំលងពីកន្លែងមួយទៅកន្លែងមួយទៀត។

~ជៀសវាងធ្វើការប្រមូលផលការ៉ុតនៅក្នុងលក្ខខណ្ឌមានសំណើមខ្លាំង។

**វិធានការកម្ចាត់:**

~ ធ្វើការប្រមូល និងកម្ទេចចោលរាល់រុក្ខជាតិដែលមានជំងឺ

~ បាញ់ថ្នាំគីមីកសិកម្មដែលមានធាតុសកម្ម Copper oxychloride ចំនួន៦០ក្រាមលាយនឹងទឹក ចំនួន២០លីត្រ។ ហើយអាចបាញ់លើកទី២ម្តងទៀតនៅរយៈពេល២សប្តាហ៍ក្រោយពេលបាញ់ លើកទី១ ការបាញ់ថ្នាំប្រភេទនេះគឺអាចបាញ់ច្រើនបំផុត២ដងប៉ុណ្ណោះក្នុងមួយរដូវដាំដុះ។

## ២. សត្វល្អិតលើដំណាំការ៉ុត:

### ២.១. ដង្កូវឃោលខោង:

**វិធានការការពារ :**

~ត្រូវអានការណែនាំនៅលើស្លាកសញ្ញានៃផលិតផលនីមួយៗឱ្យបានច្បាស់លាស់ ដូចជាកម្រិត ណែនាំ និងដែនកំណត់នៃចំនួនត្រូវប្រើប្រាស់។

~ ត្រូវធ្វើការត្រួតពិនិត្យដំណាំឱ្យបានទៀងទាត់ និងប្រើថ្នាំសម្លាប់សត្វល្អិតនៅពេលដែលកម្រិតនៃការខូចខាតរបស់ដំណាំមានច្រើន និងត្រូវបាញ់តែតំបន់ណាដែលត្រូវការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតតែប៉ុណ្ណោះ

~ ត្រូវបាញ់ដូរមុខថ្នាំសម្លាប់សត្វល្អិត។ ការប្រើប្រាស់សារធាតុគីមីក្នុងក្រុមតែមួយអាចនាំឱ្យមានការវិវឌ្ឍន៍នៃភាពស៊ាំកាន់តែលឿន

~ ការពារសត្វល្អិតមានប្រយោជន៍តាមរយៈនៃការបាញ់ថ្នាំពួក Bacillus thuringiensis (Bt) ដែលវាសម្លាប់ តែពពួកសត្វល្អិតចង្រៃតែប៉ុណ្ណោះមិនប៉ះពាល់ដល់សត្វមានប្រយោជន៍នោះទេ

~ ហាមមិនឱ្យលាយថ្នាំសត្វល្អិតច្រើនមុខបញ្ចូលគ្នានោះទេ

~ អនុវត្តវិធានការអនាម័យចម្ការឱ្យបានស្អាត ដូចជាត្រូវសម្អាតស្មៅដែលដុះក្នុងចម្ការ និងកាកសំណល់ដំណាំពីរដូវមុន។

**វិធានការកម្ចាត់:**

ដំណាក់កាលដែលល្អបំផុត ក្នុងការកម្ចាត់ពួកដង្កូវយោលទោងត្រូវធ្វើក្នុងដំណាក់កាលជាកូនដង្កូវ ហើយប្រភេទថ្នាំដែលកសិករអាចប្រើប្រាស់សម្រាប់ធ្វើការកម្ចាត់ពពួកដង្កូវយោលទោង ជាប្រភេទថ្នាំបែបជីវសាស្ត្រដូចជា Bacillus thuringiensis subsp. aizawai ជាដើម និងថ្នាំគីមីកសិកម្មមួយចំនួនទៀតដែលមានធាតុសកម្មដូចជា Flubendiamide, Chlorfenapyr Chlorantraniliprole, Emamectin benzoate, Indoxacarb, Fipronil ដែលអ្នកប្រើប្រាស់ត្រូវប្រើឆ្លាស់គ្នាទៅវិញ ទៅមកដើម្បីការពារទៅនឹងភាពស៊ាំរបស់ដង្កូវ។

## IX. ការប្រមូលផល

មុនពេលប្រមូលផល ត្រូវបញ្ឈប់ការប្រើប្រាស់ថ្នាំកសិកម្មឱ្យបានពី៧-១០ថ្ងៃ ត្រូវពិនិត្យមើលទៅលើសំបកមើមមានលក្ខណៈរលោងហើយ ឬនៅ មើមគ្មានលក្ខណៈស្គោតនៅផ្នែកកណ្តាល និងមើមបានលូតចេញដីថ្នាលល្មមអាចប្រមូលផលដែរឬទេ។




*លក្ខណៈសម្បត្តិរបស់មើមដែលអាចធ្វើការប្រមូលផលបាន*

ដំណាំការ៉ុត ជាប្រភេទដំណាំដែលអាចទទួលទានស្រស់ និងឆ្អិន យើងអាចធ្វើការប្រមូលផលបាន នៅពេលដំណាំការ៉ុតមានអាយុចាប់ពី៣ទៅ៤ខែបន្ទាប់ពីដាំរួច។ ចំពោះរយៈពេលនៃការប្រមូលផលវាអាស្រ័យទៅលើប្រភេទពូជនីមួយៗ។ គេត្រូវការផ្តាច់ទឹក ឬឈប់ស្រោចស្រព មុនពេលប្រមូលផល យ៉ាងហោចណាស់ឱ្យបានមុនពី២ទៅ៣សប្តាហ៍ដែរ ដើម្បីឱ្យមើមការ៉ុតមានរស់ជាតិផ្អែម និងសម្បូរជីវជាតិ។ ប៉ុន្តែយើងក៏អាចធ្វើការស្រោចស្រពបានដែរ តែត្រូវស្ថិតក្នុងកម្រិតតិចទួចៗ ដោយមិនឱ្យជោគជាំពេក និងជារៀងរាល់ថ្ងៃនោះទេ។ ពិសេសនៅពេលត្រូវដកត្រូវស្រោចទឹកឱ្យជោគនៅពេលល្ងាច។ វិធីសាស្រ្តក្នុងការប្រមូលផលការ៉ុតត្រូវដកយកទាំងឫសតែម្តង ហើយបន្ទាប់មក គេធ្វើការកាត់ផ្នែកលើក្បាល

របស់មើមការ៉ុតចេញ និងលាងសំអាតឱ្យបានល្អ។ ចំពោះទិន្នផលដែលយើងអាចនឹងទទួលបាន អាចចាប់ពី២៥ ទៅ៣០តោន/ហ.ត ចំពោះទិន្នផលនេះទៀតសោត ក៏អាស្រ័យទៅនឹងកត្តាជាច្រើនមានដូចជា លក្ខខណ្ឌអាកាសធាតុ ពូជ បច្ចេកទេសដាំដុះ និងកត្តារួមផ្សំមួយចំនួនទៀតផងដែរ។







១. បច្ចេកទេសក្រោយពេលប្រមូលផល:

ដំណាំការ៉ុត ត្រូវបានគេចាត់ថ្នាក់ដោយយោងតាមទំហំ និងប្រវែងរបស់វា ជាងនេះទៀត គេក៏អាចធ្វើការកំណត់ទៅតាមលក្ខណៈទ្រង់ទ្រាយ ភាពរលោង និងភាពហាប់របស់សាច់ការ៉ុតជាដើម។ ត្រូវដកចេញនូវប្រភេទមើមដែលមានការខូចខាតនានា ដូចជា រលួយ មានស្នាមសត្វ

ល្អិតបំផ្លាញ មានការប៉ះទង្គិច បណ្ដាលមកពីការប្រមូលផល មិនមានការប្រុងប្រយ័ត្ន និងកត្តាផ្សេងមួយចំនួនទៀត។

**២. ការជ្រើសរើស ឬបែងចែកចំណាត់ថ្នាក់:**

ក្រោយការប្រមូលផល ត្រូវធ្វើការបែងចែកមើមជាបីប្រភេទ:

- ប្រភេទលេខ១ ត្រូវជ្រើសមើមដែលធំជាងគេ
- ប្រភេទលេខ២ ត្រូវជ្រើសមើមដែលធំល្មម
- ប្រភេទលេខ៣ ត្រូវជ្រើសមើមដែលមានខ្នែង ឬមានការប៉ះទង្គិច បាក់បែក ដើម្បីយកទៅកែច្នៃ
- ត្រូវកាត់តម្រឹមឫសកែវ ឫសស្មែងវែងៗដែលនៅជាប់មើមរបស់វាចេញ និងកាត់ស្លឹកដោយទុកចម្ងាយពីមើមប្រហែល៥-១០ស.ម



មើមការ៉ុតមិនទាន់កាត់ឫស



មើមការ៉ុតកាត់ឫសរួច

**៣. ការវេចខ្ចប់:**

ត្រូវធ្វើការវេចខ្ចប់មើមការ៉ុតទៅតាមចំណាត់ថ្នាក់របស់វាពីលេខ១-៣ ដោយដាក់មើមរបស់វាផ្ទុយគ្នា ដាក់ទៅក្នុងកញ្ចេ ឬឡាំង ការរៀបចំបែបនេះធ្វើឱ្យយើងងាយស្រួលតម្រៀប និងដាក់មើមការ៉ុតបានច្រើន។ តែបើដាក់ក្នុងថង់ប្លាស្ទិកត្រូវរៀបមើមការ៉ុតបណ្ដោយគ្នាវិញ។

### ៨. ការស្តុកទុក:

ប្រសិនបើយើងដកភ្លាម ហើយយកទៅប្រើប្រាស់ភ្លាម យើងអាចលាងទឹកមើមការ៉ុតបាន។ ព្រោះការលាងទឹកធ្វើឱ្យយើងមិនអាចទុកយូរបានទេ គឺបានត្រឹមតែ២-៣ថ្ងៃតែប៉ុណ្ណោះ។ តែបើយើងទុកមើមដំឡូងដែលបានលាងរួចយូរជា២-៣ថ្ងៃ ធ្វើឱ្យមើមការ៉ុតរលួយផ្អែកពីខាងក្នុង។ គេអាចរក្សាទុកបានរយៈ៧ថ្ងៃ លុះត្រាតែយើងយកដីខ្សាច់ទៅក្រាលនៅបាតកញ្ជែដែលមានប្រហោងខ្យល់ ហើយយកក្រណាត់ដែលជក់ទឹកមកជ្រលក់ទឹកឱ្យជោគ និងពូតឱ្យនៅសើមល្មម រួចគ្របពីលើ បើឃើញក្រណាត់នេះស្ងួតត្រូវបាញ់ទឹកផ្សើមពីលើក្រណាត់ជាប់ជានិច្ច។ ការធ្វើបែបនេះយើងអាចរក្សាបានរហូតដល់ទី៧ថ្ងៃ មិនមានការខូចគុណភាពឡើយ។




*មើមការ៉ុតក្រោយការប្រមូលផល និងលាងសម្អាត*

### ៩. ការដឹកជញ្ជូន:

~ ការដឹកជញ្ជូនតាមម៉ូតូ រ៉ឺម៉ក ឬរថយន្តមកលក់នៅទីផ្សារត្រូវត្រូវតម្រៀបមើមជាថ្នាក់

~ ជៀសវាងការដាក់ត្រួតលើគ្នា នាំឱ្យមានការប៉ះទង្គិច បង្កឱ្យមានការបាក់ បែក ធ្វើឱ្យបាត់បង់ប្រាក់ចំណូល








**អាសយដ្ឋាន** : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចម្ការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : ០១២ ៩២ ៦៨ ៩២/០១៥ ៥៩ ២០ ២៧

**ទូរសារលេខ** : ០២៣ ២១ ០៩ ៤៨

Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម/Department of Agricultural Extension

**គេហទំព័រ** : http://www.khmeragri.info/wordpress


